# សារលិខិតរបស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ
# សម្រាប់ ទិវាពិភពលោកនៃជីដូនជីតា និងមនុស្សចាស់ លើកទី៣

***(នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣)***

*«ព្រះអង្គមានព្រះហឫទ័យមេត្តាករុណា*
*ដល់អស់អ្នកដែលកោតខ្លាចព្រះអង្គនៅគ្រប់ជំនាន់តរៀងទៅ» (លក ១,៥០)*

បងប្អូនជាទីស្រឡាញ់!

*«ព្រះអង្គមានព្រះហឫទ័យមេត្តាករុណា ដល់អស់អ្នកដែលកោតខ្លាចព្រះអង្គនៅគ្រប់ជំនាន់តរៀងទៅ» (លក ១,៥០)* ។ នេះជាប្រធានបទ សម្រាប់ទិវាពិភពលោកសម្រាប់ជីដូនជីតា និងមនុស្សចាស់ លើកទី៣។ ប្រធានបទនេះ នាំយើងត្រឡប់ទៅការជួបគ្នាដោយអំណរសប្បាយរវាង យុវនារី ម៉ារី និងបងស្រីអេលីសាបិត ដែលមានវ័យចំណាស់ *(លក ១,៣៩-៥៦)*។ នាងអេលីសាបិតបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ថ្លែងទៅកាន់មាតារបស់ព្រះជាម្ចាស់ ដោយពាក្យសំដីដែលរាប់ពាន់ឆ្នាំក្រោយមក បន្តបន្លឺឡើងនៅក្នុងការអធិដ្ឋានប្រចាំថ្ងៃរបស់យើង៖ *«ព្រះជាម្ចាស់បានប្រទានពរដល់នាងលើសស្ត្រីនានា ហើយព្រះអង្គក៏ប្រទានពរដល់បុត្រនាងដែរ។» (លក ១,៤២)*។ ព្រះវិញ្ញាណដ៏វិសុទ្ធដែលបានសណ្ឋិតលើនាងម៉ារី បានជំរុញនាងឲ្យឆ្លើយតបដោយពាក្យ អស់ពីដួងចិត្ត (Magnificat) ដែលនាងបានប្រកាសថា ធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ស្ថិតនៅគ្រប់ជំនាន់តរៀងទៅ។ ព្រះវិញ្ញាណដ៏វិសុទ្ធ ប្រទានពរ និងអមដំណើររាល់ការជួបគ្នាប្រកបដោយផ្លែផ្ការវាងមនុស្សជំនាន់ផ្សេងៗគ្នា រវាងជីដូនជីតា និងចៅៗ រវាងក្មេងៗ និងមនុស្សចាស់។ ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យមនុស្សវ័យក្មេង នាំមកនូវអំណរសប្បាយដល់មនុស្សចាស់ ហើយទទួលបានប្រាជ្ញាពីបទពិសោធន៍របស់ពួកគេ ដូចនាងម៉ារីបានធ្វើចំពោះនាងអេលីសាបិត។ ប៉ុន្តែ សំខាន់ជាងនេះទៅទៀត ព្រះអម្ចាស់មិនចង់ឲ្យយើងទុកមនុស្សចាស់ឲ្យនៅតែឯង ហើយកុំឲ្យយើងបោះបង់ពួកគេចោល ឲ្យទៅជាយនៃជីវិត ដូចអ្វីដែលជាអកុសលបានកើតឡើងជាញឹកញាប់សព្វថ្ងៃនេះ។

ឆ្នាំនេះ ការប្រារព្ធទិវាពិភពលោកសម្រាប់ជីដូនជីតា និងមនុស្សចាស់ និងការប្រារព្ធទិវាយុវជនពិភពលោកស្ថិតនៅជិតគ្នា។ ការប្រារពិធីទាំងពីរនេះរំឭកយើងអំពី *«ការប្រញាប់» ( លក១,៣៩ )* ដែលនាងម៉ារីបានចេញទៅសួរសុខទុក្ខនាងអេលីសាបិត។ ហេតុនេះ ពួកគេអញ្ជើញយើងឲ្យគិតអំពីចំណងមិត្តភាពរវាងយុវជន និងមនុស្សចាស់។ ព្រះអម្ចាស់រំពឹងថា តាមរយៈទំនាក់ទំនងរបស់យុវជនជាមួយមនុស្សចាស់ ពួកគេនឹងទទួលបាននូវការត្រាស់ហៅឲ្យរក្សាការចងចាំ និងទទួលស្គាល់សោភណភាពនៃការក្លាយជាផ្នែកមួយនៃប្រវត្តិសាស្ត្រដ៏ធំ។ មិត្តភាពជាមួយមនុស្សចាស់ អាចជួយយុវជនមិនឲ្យមើលឃើញជីវិតត្រឹមតែបច្ចុប្បន្ន ហើយដឹងថាអ្វីៗទាំងអស់មិនអាស្រ័យតែលើសមត្ថភាពផ្ទាល់ខ្លួនប៉ុណ្ណោះទេ។ សម្រាប់មនុស្សចាស់ វត្តមានរបស់យុវជនក្នុងជីវិតរបស់ពួកគេ អាចផ្តល់ឲ្យពួកគេនូវក្តីសង្ឃឹមថា បទពិសោធន៍របស់ពួកគេនឹងមិនបាត់បង់ឡើយ ហើយក្តីសុបិន្តរបស់ពួកគេអាចក្លាយជាការពិត។ ដំណើររបស់នាងម៉ារីទៅសួរសុខទុក្ខនាងអេលីសាបិត និងការយល់ដឹងអំពីធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ឆ្លងពីមួយជំនាន់ទៅមួយជំនាន់ ជួយបង្ហាញថា យើងមិនអាចឆ្ពោះទៅមុខតែម្នាក់ឯង និងមិនអាចសង្គ្រោះខ្លួនឯងបានឡើយ ហើយវត្តមាន និងសកម្មភាពរបស់ព្រះជាម្ចាស់ តែងតែជាផ្នែកដ៏អស្ចារ្យនៅក្នុងប្រវត្តិសាស្ត្រនៃមនុស្ស។ នាងម៉ារីផ្ទាល់បានថ្លែងសេចក្តីនេះនៅក្នុងពាក្យអធិដ្ឋាន Magnificat នៅពេលដែលនាងពោរពេញដោយអំណរនៅក្នុងព្រះជាម្ចាស់ ដ្បិតទ្រង់បានសំដែងការអស្ចារ្យជាថ្មី និងស្មានមិនដល់ ស្របតាមព្រះបន្ទូលសន្យាជាមួយលោកអាប្រាហាំ *(លក ១,៥១-៥៥)*។

ដើម្បីយល់កាន់តែច្បាស់អំពីរបៀបដែលព្រះជម្ចាស់ប្រព្រឹត្ត ចូរយើងចាំថា ជីវិតរបស់យើងត្រូវរស់នៅឲ្យបានពេញលេញ ដ្បិតក្តីសង្ឃឹម និងក្តីសុបិនដ៏អស្ចារ្យបំផុតរបស់យើង មិនអាចសម្រេចបានភ្លាមៗនោះទេ ប៉ុន្តែ វាត្រូវឆ្លងកាត់ការរីកចម្រើន និងភាពចាស់ទុំក្នុងការសន្ទនា និងទំនាក់ទំនងជាមួយអ្នកដទៃ។ ហេតុនេះហើយបានជា អស់អ្នកដែលផ្តោតតែលើបច្ចុប្បន្ន លើលុយ និងទ្រព្យសម្បត្តិ លើ «ការមានទាំងអស់ឥឡូវនេះ» ជាអ្នកបាត់បង់នូវការមើលឃើញសកម្មភាពរបស់ព្រះជាម្ចាស់។ គម្រោងការនៃសេចក្តីស្រឡាញ់របស់ព្រះអង្គ លាតសន្ធឹងពីអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល គ្របដណ្តប់ និងភ្ជាប់គ្រប់ជំនាន់។ គម្រោងការនេះហួសពីគំនិតរបស់យើង ប៉ុន្តែយើងម្នាក់ៗមានសារសំខាន់ ហើយអញ្ជើញយើងឲ្យបន្តដំណើរទៅមុខគ្រប់ពេលវេលា។ សម្រាប់យុវវ័យ នេះគឺជាការប្រុងប្រៀបរំដោះខ្លួន ឲ្យរួចពីវត្តមានដ៏ខ្លីមួយ ដែលការពិតនិម្មិតអាចចាប់យើង ដោយរារាំងយើងពីការធ្វើអ្វីមួយដែលមានប្រយោជន៍។ សម្រាប់មនុស្សចាស់ នេះមានន័យថា កុំរស់នៅលើការបាត់បង់កាយសម្បទា ហើយក៏មិនត្រូវសោកស្តាយចំពោះឱកាសដែលបានបាត់បង់។ ចូរយើងសម្លឹងទៅអនាគត! ចូរទុកឲ្យព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ កែឆ្នៃខ្លួនយើង ដោយរំដោះយើងគ្រប់ជំនាន់ពីនិចលភាព និងពីការសោកស្តាយអតីតកាល។

ក្នុងការជួបគ្នារវាងនាងម៉ារី និងនាងអេលីសាបិត រវាងយុវជន និងមនុស្សចាស់ ព្រះជាម្ចាស់ផ្តល់អនាគតរបស់ព្រះអង្គមកឲ្យយើង។ ជាការពិតណាស់ ការសួរសុខទុក្ខរបស់នាងម៉ារី និងការស្វាគមន៍របស់អេលីសាបិត បើកទ្វារសម្រាប់ការសំដែងអំពីការសង្គ្រោះ ៖ តាមរយៈការឱបរបស់អ្នកទាំងពីរ ធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ បានចូលក្នុងប្រវត្តិសាស្ត្រមនុស្សដោយស្ងៀមស្ងាត់ និងពោលពេញដោយអំណរដ៏លើសលប់។ ខ្ញុំលើកទឹកចិត្តអ្នករាល់គ្នាឲ្យសញ្ជឹងគិតអំពីការជួបគ្នានេះ ដោយស្រមៃឃើញការឱបក្រសោបរវាងមាតាវ័យក្មេងរបស់ព្រះជាម្ចាស់ និងម្តាយចាស់របស់សន្តយ៉ូហានបាទីស្ត ហើយសូមបង្ហាញរូបភាពនេះដូចជារូបថតមួយសន្លឹកនៅក្នុងចិត្ត និងឆ្លាក់នៅក្នុងព្រលឹងដូចជារូបអ៊ីកូនមួយ (Icon) ដែលភ្លឺថ្លាពីខាងក្នុង។

បន្ទាប់មកទៀត ខ្ញុំសូមអញ្ជើញអ្នករាល់គ្នា ឲ្យឆ្លងពីការស្រមើស្រមៃ ទៅរកសកម្មភាពជាក់ស្តែង ដោយកាយវិការមួយដើម្បីឱបជីដូនជីតា និងមនុស្សចាស់។ សូមកុំបោះបង់ពួកគេឲ្យនៅតែឯង។ វត្តមានរបស់ពួកគេនៅក្នុងគ្រួសារ និងសហគមន៍ ជាអ្វីមួយដ៏មានតម្លៃ ព្រោះវារំឭកយើងថា យើងចែករំលែកមរតកតែមួយ និងធ្វើជាផ្នែកមួយនៃប្រជាជនដែលរក្សាឫសគល់របស់ខ្លួន។ តាមរយៈមនុស្សចាស់ យើងបានទទួលអំណោយជាកម្មសិទ្ធិនៃប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះអង្គ។ ព្រះសហគមន៍ ក៏ដូចជាសង្គមដែរ គឺត្រូវការពួកគេ ពីព្រោះពួកគេរៀបចំអតីតកាលសម្រាប់បច្ចុប្បន្ន ដែលជាតម្រូវការដ៏ចាំបាច់សម្រាប់កសាងអនាគត។ ចូរយើងគោរពពួកគេ កុំឲ្យយើងចាកចេញពីការរួមដំណើររបស់ពួកគេ ហើយកុំឲ្យពួកគេចាកចេញពីការរួមដំណើររបស់យើង។ សូមកុំបោះបង់មនុស្សចាស់ចោលឡើយ!

ទិវាពិភពលោក សម្រាប់ជីដូនជីតា និងមនុស្សចាស់ មានន័យថា ជាអ្វីមួយដ៏តូច ប៉ុន្តែជាសញ្ញាដ៏មានតម្លៃនៃក្តីសង្ឃឹមសម្រាប់ពួកគេ និងសម្រាប់ព្រះសហគមន៍ទាំងមូល។ ខ្ញុំសូមបន្តការអញ្ជើញរបស់ខ្ញុំទៅកាន់អ្នករាល់គ្នា - គ្រប់ភូមិភាគ ព្រះសហគមន៍ សមាគមន៍ និងសហគមន៍ - ឲ្យប្រារព្ធទិវានេះ និងធ្វើឲ្យវាក្លាយទៅជាឱកាសមួយនៃអំណរសប្បាយ និងបន្តការជួបជុំគ្នារវាងយុវជន និងមនុស្សចាស់។ ចំពោះយុវជន ដែលត្រៀមខ្លួនទៅជួបជុំនៅទីក្រុងលីសបន (Lisbon) ឬប្រារព្ធទិវាយុវជនពិភពលោកនៅក្នុងប្រទេសរបស់ខ្លួន ខ្ញុំចង់ផ្តាំផ្ញើថា៖ មុនពេលកូនៗចេញដំណើរ សូមទៅសួរសុខទុក្ខជីដូនជីតារបស់ខ្លួន ឬមនុស្សចាស់ដែលរស់នៅម្នាក់ឯង! ការអធិដ្ឋានរបស់ពួកគេនឹងតាមការពារកូន ហើយកូននឹងទទួលព្រះពរពីការជួបគ្នានោះ នៅក្នុងចិត្ត។ សម្រាប់មនុស្សចាស់ក្នុងចំណោមពួកយើង ខ្ញុំសូមឲ្យរួមដំណើរជាមួយយុវជន ដែលកំពុងត្រៀមខ្លួនប្រារព្ធទិវាយុវជនពិភពលោកដោយការអធិដ្ឋាន។ យុវជនទាំងនោះ គឺជាចម្លើយរបស់ព្រះជាម្ចាស់ចំពោះការអធិដ្ឋានរបស់អ្នករាល់គ្នា ជាផលផ្លែនៃអ្វីៗដែលអ្នករាល់គ្នាបានសាបព្រោះ ហើយជាសញ្ញាបញ្ជាក់ថា ព្រះជាម្ចាស់មិនបោះបង់រាស្ត្ររបស់ព្រះអង្គចោលឡើយ ប៉ុន្តែ តែងតែធ្វើឲ្យពួកគេ មានភាពរស់រវើកឡើងវិញ ដោយការច្នៃប្រឌិតរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។

ជីដូនជីតាជាទីស្រឡាញ់ លោកតា លោកយាយជាទីគោរព សូមឲ្យព្រះពរនៃការឱបក្រសោបរវាងនាងម៉ារី និងនាងអេលីសាបិត កើតមានដល់អ្នក ហើយបំពេញដួងចិត្តរបស់អ្នករាល់គ្នាដោយសន្តិភាព។ ខ្ញុំសូមប្រទានពរអ្នករាល់គ្នាដោយក្តីស្រឡាញ់ដ៏ខ្ពង់ខ្ពស់ ។ ហើយសូមអ្នករាល់គ្នាអធិដ្ឋានសម្រាប់ខ្ញុំផង។

*ធ្វើនៅទីក្រុងរ៉ូម ព្រះវិសាលវិហារសន្តយ៉ូហាន ឡាត្រង់*
*ក្នុងឱកាសបុណ្យគោរព ការសួរសុខទុក្ខរបស់ព្រះនាងម៉ារី*
*ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣*

**សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ**